ព្រឹទ្ធសភា
អគ្គលេខាធិការដ្ឋាន

# របាយការណ៍
# ស្តីពី
# លទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែមេសា និងទិសដៅការងារខែឧសភា ឆ្នាំ២០២២

នៅក្នុងខែមេសានេះ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានខិតខំបំពេញការងារយ៉ាងសកម្ម តាមបែបគន្លងថ្មី លើវិស័យនៃការងារសំខាន់ៗជាច្រើន ដើម្បីផ្តល់សេវាជូនថ្នាក់ដឹកនាំ និងសមាជិក សមាជិកាព្រឹទ្ធសភា ក្នុងការអនុវត្តមុខងាររបស់ខ្លួនដោយទទួលបានលទ្ធផលសំខាន់ៗ ដូចខាងក្រោម៖

## I-លទ្ធផលការងារសម្រេចបានលើមុខងារទាំង៥៖

### ១- មុខងារនីតិកម្ម

- បានរៀបចំចាត់ចែងប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភាចំនួន០២លើក និងប្រជុំពេញអង្គព្រឹទ្ធសភា នីតិកាលទី៤ ដើម្បីពិនិត្យ និងឱ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពី ការការពាររុក្ខជាតិ និងភូតគាមអនាម័យ

- បានរៀបចំចាត់ចែងជូនសមាជិកព្រឹទ្ធសភា ប្រជុំជាមួយតំណាងរាជរដ្ឋាភិបាល ដើម្បីពិនិត្យសិក្សាលើសេចក្តីព្រាងច្បាប់ចំនួន០១ច្បាប់

- បានផ្តល់សេវាជូនសមាជិកគណៈកម្មការទី២ ព្រឹទ្ធសភា អញ្ជើញជាអធិបតីក្នុងកិច្ចប្រជុំគណៈកម្មការច្បាប់ និងនីតិវិធីបោះឆ្នោតស្តីពី ផែនការឆ្ពោះទៅការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២ នៅរាជធានីភ្នំពេញ។

### ២- មុខងារតាមដានការអនុវត្តច្បាប់

- បានរៀបចំបែបបទ ផ្តល់សេវា និងអមដំណើរសមាជិក សមាជិកាព្រឹទ្ធសភា៖

+អញ្ជើញចុះបំពេញបេសកកម្មសិក្សាឈ្វេងយល់អំពីការអនុវត្តច្បាប់អន្តោប្រវេសន៍ ការផ្សព្វផ្សាយព័ត៌មាន និងការអភិវឌ្ឍលើវិស័យនានារបស់ខេត្តកោះកុង ខេត្តព្រះសីហនុ និងខេត្តកំពត និងចុះពិនិត្យនៅតាមច្រកទ្វារព្រំដែនអន្តរជាតិចាំយាម នៃស្រុកមណ្ឌលសីមា



វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ខេត្តកោះកុង នៅកំពង់ផែស្វយ័តក្រុងព្រះសីហនុ ខេត្តព្រះសីហនុ និងនៅតាមច្រកទ្វារព្រំដែនអន្តរជាតិព្រែកចាក នៃស្រុកកំពង់ត្រាច ខេត្តកំពត

+អញ្ជើញចុះបំពេញបេសកកម្មសិក្សាឈ្វេងយល់ព័ត៌មានស្តីពី "ការអភិវឌ្ឍឃុំកែវផុសរយៈពេល៥ឆ្នាំ ដោយប្រើប្រាស់ថវិការបស់រាជរដ្ឋាភិបាល និងទស្សនកិច្ចតំបន់អភិវឌ្ឍន៍កសិ-ឧស្សាហកម្មឧកញ៉ា **ម៉ុង ឬទ្ធី**" ស្ថិតក្នុងឃុំកែវផុស ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ

+អញ្ជើញចុះបំពេញបេសកកម្មសិក្សាឈ្វេងយល់ និងសម្រង់ព័ត៌មានពាក់ព័ន្ធទៅនឹងវិស័យជាសមត្ថកិច្ចរបស់គណៈកម្មការ នៅខេត្តកំពង់ស្ពឺ

+អញ្ជើញចុះបំពេញបេសកកម្មសិក្សាឈ្វេងយល់អំពីសិប្បកម្មតម្បាញហូល ផាមួង ក្រមា កញ្ចើ ល្អី និងសម្ភារប្រើប្រាស់កែច្នៃដោយដៃ នៅខេត្តពោធិ៍សាត់ និងខេត្តកំពង់ធំ

+អញ្ជើញចុះបំពេញបេសកកម្មសិក្សាឈ្វេងយល់ និងប្រមូលព័ត៌មានអំពីវឌ្ឍនភាព និងបញ្ហាផ្សេងៗ នៅខេត្តកំពង់ធំ និងខេត្តស្ទឹងត្រែង

+អញ្ជើញចុះជួបសំណេះសំណាល និងពិភាក្សាការងារជាមួយថ្នាក់ដឹកនាំខណ្ឌ និងក្រុមប្រឹក្សាសង្កាត់ទាំងអស់ក្នុងខណ្ឌទួលគោក ខណ្ឌសែនសុខ និងខណ្ឌជ្រោយចង្វារ រាជធានី-ភ្នំពេញ

+អញ្ជើញចុះជួបសំណេះសំណាល សួរសុខទុក្ខ និងពិភាក្សាការងារជាមួយសមាជិកក្រុមប្រឹក្សាឃុំ នៅខេត្តតាកែវ និងខេត្តបាត់ដំបង

+អញ្ជើញចុះជួបពិភាក្សាការងារជាមួយអាជ្ញាធរមូលដ្ឋាន ដើម្បីឈ្វេងយល់អំពីវឌ្ឍនភាពនៃការអភិវឌ្ឍស្រុក-ឃុំ ការងារសន្តិសុខ សណ្តាប់ធ្នាប់ និងការផ្តល់សេវាសាធារណៈនៅខេត្តព្រៃវែង

+អញ្ជើញចុះជួបពិភាក្សាការងារជាមួយអាជ្ញាធរមូលដ្ឋាន ដើម្បីឈ្វេងយល់អំពីការអនុវត្តតួនាទីរបស់ក្រុមប្រឹក្សាឃុំ-សង្កាត់ និងគោលនយោបាយភូមិ-ឃុំ មានសុវត្ថិភាព នៅខេត្តស្ទឹងត្រែង និងខេត្តរតនគិរី

+អញ្ជើញចុះជួបពិភាក្សាការងារជាមួយក្រុមប្រឹក្សាឃុំ-សង្កាត់ ជាស្ត្រី នៅខេត្តកំពត និងខេត្តកែបៗ

**៣- មុខងារតំណាង**

- បានរៀបចំទីកន្លែង និងផ្តល់សេវាក្នុងកិច្ចប្រជុំពិភាក្សាការងាររវាង**សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រធានព្រឹទ្ធសភា** ជាមួយឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **អ៊ឹម ឈុនលឹម** ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ និងពិធីជួបជុំជាមួយសមាជិកព្រឹទ្ធសភា នៅសាលសិក្ខាសាលាខាងជើងព្រឹទ្ធសភា

-បានផ្តល់សេវា និងអមដំណើរ**សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រធានព្រឹទ្ធសភា** អញ្ជើញចូលរួមទទួលព្រះរាជដំណើររបស់**ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា និង**សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ** ព្រះវររាជមាតាជាតិខ្មែរ ស្តេចយាងនិវត្តន៍ពីទីក្រុងប៉េកាំង នៃសាធារណរដ្ឋប្រជាមានិតចិន និងអញ្ជើញប្រារព្ធពិធីបង្សុកូល ដើម្បីឧទ្ទិសកុសលជូនមាតា បិតា ញាតិកាទាំង៧សន្តាន នៅវត្តនាគវ័ន្ត រាជធានីភ្នំពេញ និងវត្តសុវណ្ណគិរី ខេត្តកំពង់ចាម, ចូលរួមគោរពវិញ្ញាណក្ខន្ធសពមហាឧបាសិកា **តាន់ វ៉ាយ** ម្តាយបង្កើតរបស់ឯកឧត្តម **កៅ ខុនដារ៉ា** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ នៅខេត្តព្រះសីហនុ និងជួបសំណេះសំណាល សាកសួរសុខទុក្ខប្រជាពលរដ្ឋ នៅរាជធានីភ្នំពេញ ព្រមទាំងចុះសួរសុខទុក្ខឯកឧត្តម **ប៊ុន សម** ដែលសម្រាកព្យាបាលជំងឺ នៅគេហដ្ឋាន

-បានផ្តល់សេវា និងអមដំណើរ**ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ស៊ឹម កា ប្រធានស្តីទីព្រឹទ្ធសភា** អញ្ជើញចុះជួបសំណេះសំណាល និងពិភាក្សាការងារជាមួយថ្នាក់ដឹកនាំខណ្ឌ និងប្រធានក្រុមប្រឹក្សាសង្កាត់ នៅខណ្ឌព្រែកព្នៅ ខណ្ឌច្បារអំពៅ ខណ្ឌ៧មករា ខណ្ឌដូនពេញ ខណ្ឌបឹងកេងកង ខណ្ឌឫស្សីកែវ ខណ្ឌទួលគោក ខណ្ឌសែនសុខ ខណ្ឌជ្រោយចង្វារ ខណ្ឌចំការមន ខណ្ឌដង្កោ ខណ្ឌមានជ័យ ខណ្ឌពោធិ៍សែនជ័យ និងខណ្ឌកំបូល ដើម្បីឈ្វេងយល់អំពីសភាពការណ៍រួមក្នុងមូលដ្ឋាន ការងារសន្តិសុខ សណ្តាប់ធ្នាប់ ពិនិត្យណែនាំអំពីការផ្តល់សេវាសាធារណៈឱ្យបានល្អ និងការត្រៀមលក្ខណៈសម្រាប់ការបោះឆ្នោតឃុំ-សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២ នាពេលខាងមុខ

-បានផ្តល់សេវា និងអមដំណើរ**ឯកឧត្តមកិត្តិសង្គហបណ្ឌិត ទេព ងន អនុប្រធានទី២ព្រឹទ្ធសភា** អញ្ជើញជាគណៈអធិបតីក្នុងពិធីសំណេះសំណាល និងសាកសួរសុខទុក្ខអាជ្ញាធរ ក្រុមប្រឹក្សាឃុំ-សង្កាត់ ទូទាំងខេត្តកណ្តាលសរុបចំនួន១,១៧៧នាក់ និងអញ្ជើញនាំយកទេយ្យទានទៅប្រគេនព្រះសង្ឃនៅវត្តប្រាំបីមុំ ខេត្តតាកែវ ព្រមទាំងចូលរួមក្នុងពិធីបុណ្យបញ្ចុះសពមហាឧបាសិកា **តាន់ វ៉ាយ** ម្តាយបង្កើតរបស់ឯកឧត្តម **កៅ ខុនដារ៉ា** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ នៅខេត្តព្រះសីហនុ

-បានរៀបចំបែបបទ ផ្តល់សេវា និងអមដំណើរសមាជិកព្រឹទ្ធសភា អញ្ជើញចុះមូលដ្ឋាន ដើម្បីជួបសំណេះសំណាល សាកសួរសុខទុក្ខប្រជាពលរដ្ឋ ក្រុមប្រឹក្សាឃុំ-សង្កាត់ អាជ្ញាធរគ្រប់លំដាប់ថ្នាក់ ដើម្បីឈ្វេងយល់អំពីវឌ្ឍនភាពការងារ បញ្ហាប្រឈមនៃការផ្តល់សេវាសាធារណៈ គោលនយោបាយភូមិ-ឃុំ មានសុវត្ថិភាព ពិនិត្យហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ សម្ពោធសមិទ្ធផលនានា ដោះស្រាយទុក្ខលំបាករបស់ប្រជាពលរដ្ឋ និងបញ្ហាប្រឈមនានា ផ្សព្វផ្សាយអំពីវិធានការរបស់

ក្រសួងសុខាភិបាលស្តីពី វិធីការពារខ្លួនពីជំងឺរាតត្បាតកូវីដ-១៩ ជាពិសេសអប់រំប្រជាពលរដ្ឋឱ្យរៀនរស់ជាមួយជំងឺកូវីដ-១៩ ចំនួន២២០លើក នៅរាជធានីភ្នំពេញ ខេត្តកំពង់ស្ពឺ ខេត្តកណ្តាល ខេត្តតាកែវ ខេត្តកំពត ខេត្តកែប ខេត្តព្រះសីហនុ ខេត្តពោធិ៍សាត់ ខេត្តបាត់ដំបង ខេត្តបន្ទាយ-មានជ័យ ខេត្តឧត្តរមានជ័យ ខេត្តសៀមរាប ខេត្តព្រះវិហារ ខេត្តស្ទឹងត្រែង ខេត្តរតនគិរី ខេត្តកំពង់ធំ ខេត្តកំពង់ឆ្នាំង ខេត្តត្បូងឃ្មុំ ខេត្តកំពង់ចាម ខេត្តព្រៃវែង និងខេត្តស្វាយរៀង

- ឯកឧត្តម **អ៊ុំ សារីទ្ធ** អគ្គលេខាធិការព្រឹទ្ធសភា បានអញ្ជើញធ្វើការងារសង្គមកិច្ចជួយប្រជាជននៅសង្កាត់ជ្រោយចង្វារ សង្កាត់ព្រែកតាសេក និងសង្កាត់ព្រែកលៀប ក្នុងខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ

- ឯកឧត្តម **ឡោក ឆាយ** អគ្គលេខាធិការរងព្រឹទ្ធសភា បានអញ្ជើញធ្វើការងារសង្គមកិច្ចជួយប្រជាជននៅសង្កាត់បាក់ខែង និងសង្កាត់កោះដាច់ ក្នុងខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ

- បានរៀបចំពិធីប្រកាសឯកឧត្តម **លឹម ប៊ុនហុក** ជាអគ្គលេខាធិការរងព្រឹទ្ធសភាថ្មី

- បាននាំយកថវិការបស់**ឯកឧត្តមកិត្តិសង្គហបណ្ឌិត ទេព ងន អនុប្រធានទី២ ព្រឹទ្ធសភា** ចំនួន២០,០០០,០០០រៀល ឧបត្ថម្ភជូនកាកបាទក្រហមកម្ពុជា

- បាននាំយកថវិការបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន២,០០០,០០០រៀល ឧបត្ថម្ភជូននាយកប្រតិបត្តិនៃសមាគមចលនាវប្បធម៌ជាតិ ដើម្បីកុមារកំព្រា កុមារក្រីក្រ ក្នុងឱកាសពិធីបុណ្យចូលឆ្នាំថ្មី ប្រពៃណីជាតិខ្មែរ

- បានផ្តល់សេវាជូនក្រុមការងាររបស់**ឯកឧត្តមកិត្តិសង្គហបណ្ឌិត ទេព ងន អនុប្រធានទី២ ព្រឹទ្ធសភា** អញ្ជើញដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្តទៅពិនិត្យ និងព្យាបាលជំងឺជូនប្រជាពលរដ្ឋ នៅខេត្តកណ្តាល

- ក្នុងឱកាសពិធីបុណ្យចូលឆ្នាំថ្មី ប្រពៃណីជាតិខ្មែរ ឯកឧត្តម លោកជំទាវ ជាអគ្គនាយក អគ្គនាយិកា និងអគ្គនាយករង តំណាងឯកឧត្តមអគ្គលេខាធិការព្រឹទ្ធសភា បាននាំយកទេយ្យទានគ្រឿងឧបភោគ បរិភោគ និងបច្ច័យមួយចំនួនទៅប្រគេនព្រះសង្ឃគ្រប់វត្ត ស្ថិតក្នុងខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ

- បានទទួលពាក្យបណ្តឹងចំនួន០៦រណើ បញ្ជូនពាក្យបណ្តឹងទៅក្រសួង រាជធានី ខេត្ត និងស្ថាប័នពាក់ព័ន្ធចំនួន០៣ករណី កំពុងពិនិត្យសិក្សាចំនួន០៨ករណី ធ្វើកំណត់បង្ហាញពាក្យបណ្តឹងចំនួន០៣ករណី ឆ្លើយតបទៅម្ចាស់បណ្តឹងចំនួន០៣ករណី ព្រមទាំងទទួលឯកសារជូនជ្រាបពីក្រសួង ស្ថាប័នពាក់ព័ន្ធចម្លងជូនគណៈកម្មការចំនួន០៣ករណី

- បានផ្សព្វផ្សាយវីដេអូសមិទ្ធផលព្រឹទ្ធសភាស្តីពី "ការអភិវឌ្ឍរយៈពេល១ឆ្នាំ ក្នុងឆ្នាំទី២ ព្រឹទ្ធសភា នីតិកាលទី៤" ក្នុងឱកាសអបអរសាទរខួបឆ្នាំទី២ នៃថ្ងៃបើកសម័យប្រជុំដំបូងព្រឹទ្ធសភា នីតិកាលទី៤

- បានចាត់ចែងបញ្ជូនសារលិខិតជូនពររបស់ថ្នាក់ដឹកនាំព្រឹទ្ធសភា គោរពជូន និងទូលថ្វាយ **ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា, **សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ** ព្រះវររាជមាតាជាតិខ្មែរ, **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី, **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុន សែន** ប្រធានកាកបាទក្រហមកម្ពុជា និង**សម្តេចអគ្គមហាពញាចក្រី ហេង សំរិន** ប្រធានរដ្ឋសភា ព្រមទាំងឥស្សរជនជាន់ខ្ពស់តាមក្រសួង-ស្ថាប័ននានា ក្នុងឱកាសពិធីបុណ្យចូលឆ្នាំថ្មី ប្រពៃណីជាតិខ្មែរ និងចម្រើនជន្មាយុ

- បានចាត់ចែងបញ្ជូនសារលិខិតជូនពររបស់ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ជូនថ្នាក់ដឹកនាំ និងសមាជិកព្រឹទ្ធសភា ព្រមទាំងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ក្នុងឱកាសពិធីបុណ្យចូលឆ្នាំថ្មី ប្រពៃណីជាតិខ្មែរ

- បានផ្ញើសាររំលែកទុក្ខជូនគ្រួសារសពមន្ត្រីជាន់ខ្ពស់ចំនួន០២លើក

- បានបោះពុម្ពសៀវភៅ "**សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រធានព្រឹទ្ធសភា** ទទួលជួបភ្ញៀវអន្តរជាតិ (ឆ្នាំ២០១២- ២០២១)" ចំនួន៣០ក្បាល

- បានផលិតទស្សនាវដ្តីប្រចាំខែមេសា ឆ្នាំ២០២២ ចំនួន៨០០ក្បាល

- បានតុបតែងលម្អ និងរៀបចំពិធីសូត្រមន្តអបអរសាទរពិធីបុណ្យចូលឆ្នាំថ្មី ប្រពៃណីជាតិខ្មែរ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៥។

**៤- មុខងារសហប្រតិបត្តិការអន្តរជាតិ**

- បានរៀបចំទីកន្លែង និងផ្តល់សេវាក្នុងពិធីជំនួបសម្តែងការគួរសម ជូន**សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រធានព្រឹទ្ធសភា** ជាមួយឯកឧត្តម OM BIRLA ប្រធានរដ្ឋសភា នៃសាធារណរដ្ឋឥណ្ឌា និងឯកឧត្តម **ឱញ ទៀន ហ៊ុរុង** សមាជិកការិយាល័យនយោបាយបក្សកុម្មុយនីស្តវៀតណាម និងជាលេខាគណៈកម្មាធិការបក្សរដ្ឋធានីហាណូយ នៃសាធារណរដ្ឋសង្គមនិយមវៀតណាម

- បានរៀបចំចាត់ចែងជូន**សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រធានព្រឹទ្ធសភា** អញ្ជើញដឹកនាំគណៈប្រតិភូជាន់ខ្ពស់ព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា ទៅបំពេញទស្សនកិច្ចជាផ្លូវការ ដើម្បីពង្រឹងពង្រីកកិច្ចសហប្រតិបត្តិការរវាងអង្គការនីតិបញ្ញត្តិទាំងពីរ ព្រមទាំងទំនាក់ទំនង

មិត្តភាព និងកិច្ចសហប្រតិបត្តិការល្អប្រពៃរវាងប្រជាជន និងប្រទេសទាំងពីរកម្ពុជា-កូរ៉េ នៅសាធារណរដ្ឋកូរ៉េ

- បានរៀបចំចាត់ចែងជូនសមាជិកព្រឹទ្ធសភា អញ្ជើញប្រជុំត្រៀមលក្ខណៈរៀបចំមហាសន្និបាតអន្តរសភាអាស៊ាន(AIPA) លើកទី៤៣ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត **ជាម យៀប** អនុប្រធានទី១ រដ្ឋសភា និងជាប្រធានគណៈកម្មការរៀបចំមហាសន្និបាតអន្តរសភាអាស៊ាន(AIPA) លើកទី៤៣, និងកិច្ចប្រជុំក្រុមអន្តរសភាមិត្តភាពកម្ពុជា-បារាំង ដើម្បីត្រៀមទទួលគណៈប្រតិភូអន្តរសភាមិត្តភាពបារាំង-កម្ពុជា

- បានរៀបចំទីកន្លែង និងផ្តល់សេវាក្នុងពិធីជំនួបសម្តែងការគួរសម និងពិភាក្សាការងារជូនសមាជិកព្រឹទ្ធសភា ជាមួយថ្នាក់ដឹកនាំនៃក្រុមហ៊ុនផារ៉ាហ្គន និងសាកលវិទ្យាល័យអន្តរជាតិផារ៉ាហ្គន (Paragon International University), គណៈប្រតិភូចិន និងកម្ពុជា ព្រមទាំងក្រុមអ្នកវិនិយោគទុន មកពីប្រទេសអ៊ុយក្រែន

- ឯកឧត្តម **អ៊ុំ សារិទ្ធ** អគ្គលេខាធិការព្រឹទ្ធសភា បានជួបពិភាក្សាការងារជាមួយនាយិកាកម្មវិធីនុមេរិច នៃសភាប្រើប្រាស់ភាសាបារាំង និងមន្ត្រីនៃស្ថានទូតជប៉ុន ប្រចាំព្រះរាជាណាចក្រកម្ពុជា

- ឯកឧត្តម **លឹម ប៊ុនហុក** អគ្គលេខាធិការរងព្រឹទ្ធសភា បានជួបពិភាក្សាការងារជាមួយទីប្រឹក្សា និងលេខាទី១ នៃស្ថានទូតបារាំងប្រចាំព្រះរាជាណាចក្រកម្ពុជា

- បានសហការ និងទំនាក់ទំនងជាមួយស្ថានទូតចិន, ស្ថានទូតម៉ាឡេស៊ី, ស្ថានទូតព្រុយណេ, ស្ថានទូតឥណ្ឌា, ស្ថានទូតថៃ, ដៃគូភាគីចិន, ទីស្តីការគណៈរដ្ឋមន្ត្រី, អង្គការមូលនិធិអាស៊ី, សាលាភូមិន្ទរដ្ឋបាល, មជ្ឈមណ្ឌលសភាអាស៊ី(PCA), វិទ្យាស្ថាន CamKPI Professional Academy, វិទ្យាស្ថានជាតិ ប្រៃសណីយ៍ ទូរគមនាគមន៍ បច្ចេកវិទ្យា គមនាគមន៍ និងព័ត៌មាន (NIPTICT), ភ្នាក់ងារសង្គមព័ត៌មានជាតិ(NIA), ក្រុមហ៊ុនCambodia Hosting និងក្រសួង ស្ថាប័ននានា ដើម្បីសម្រួលដល់កិច្ចការអន្តរជាតិ និងស្នើសុំអាហារូបករណ៍ វគ្គបណ្តុះបណ្តាល ជំនួយ ព្រមទាំងការរៀបចំពិធីផ្សេងៗ។

**៥- មុខងារអភិវឌ្ឍន៍ស្ថាប័ន**

- បានសហការជាមួយរដ្ឋសភា និងកម្មវិធីនុយមេរិច នៃសភាប្រើភាសាបារាំង (APF) រៀបចំសិក្ខាសាលាស្តីពី ការប្រយុទ្ធប្រឆាំងព័ត៌មានក្លែងក្លាយ និងសេរីភាពសារព័ត៌មាន បញ្ហាប្រឈម និងដំណោះស្រាយ នៅវិមានព្រឹទ្ធសភា

- បានធ្វើបទឧទ្ទេសនាមស្តីពី រចនាសម្ព័ន្ធ តួនាទី ភារកិច្ចរបស់អគ្គនាយកដ្ឋានពិធីការ និងទំនាក់ទំនងអន្តរជាតិ ជូនឯកឧត្តមអគ្គលេខាធិការរងព្រឹទ្ធសភា

- បានជួបពិភាក្សាការងារជាមួយក្រុមហ៊ុន Huawei ដើម្បីស្នើសុំការគាំទ្រលើគម្រោងដូចខាងក្រោម៖

+ការរៀបចំបន្ទប់រៀន E-Learning សម្រាប់នាយកដ្ឋានអភិវឌ្ឍន៍ធនធានមនុស្ស

+ទស្សនកិច្ចសិក្សាឈ្វេងយល់ពីការរៀបចំបន្ទប់ E-learning នៅអគារធ្វើការរបស់ក្រុមហ៊ុន Huawei

+រៀបចំកម្មវិធីបាឋកថា/បទបង្ហាញរៀងរាល់សប្តាហ៍លើប្រធានបទនានា ដែលពាក់ព័ន្ធនឹងបច្ចេកវិទ្យាក៏ដូចការវិវត្តន៍នានា ក្នុងសង្គមបច្ចុប្បន្ន

- បានប្រជុំបូកសរុបលទ្ធផលការងារប្រចាំត្រីមាសទី១ និងទិសដៅការងារត្រីមាសទី២ ឆ្នាំ២០២២

- បានសិក្សា និងធ្វើបច្ចុប្បន្នភាពគោលការណ៍ និងគោលនយោបាយនានា ឱ្យបានសមស្របនឹងដំណាក់កាលថ្មីៗ

**៤.១-ការងាររដ្ឋបាល និងហិរញ្ញវត្ថុ៖**

- បានទទួលលិខិតចូលចំនួន៦៩៥ច្បាប់ និងបញ្ជូនលិខិតចេញចំនួន៣៨០ច្បាប់

- បន្តយកចិត្តទុកដាក់ចូលរួមយុទ្ធនាការប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ ការងាររក្សាអនាម័យបរិស្ថាន សំរាម សួនច្បារ និងការដាំដើមឈើ ប្រព័ន្ធទឹក លូ ថ្នល់ ចំណតរថយន្ត ការងារសន្តិសុខ និងសណ្តាប់ធ្នាប់ ដើម្បីធានាឱ្យមានផាសុកភាព និងបរិស្ថានបៃតង

- បានរៀបចំផែនការយុទ្ធសាស្ត្រ៣ឆ្នាំរំកិល (ឆ្នាំ២០២៣-២០២៥) និងគម្រោងថវិកាឆ្នាំ២០២៣ របស់ព្រឹទ្ធសភា

- បានបើកប្រាក់បៀវត្សប្រចាំខែមេសា ឆ្នាំ២០២២ និងប្រាក់ឧបត្ថម្ភផ្សេងៗ ជូនសមាជិកព្រឹទ្ធសភា និងមន្ត្រីរាជការ បុគ្គលិកជាប់កិច្ចសន្យា ទីប្រឹក្សា ជំនួយការ អ្នកបើកបរ និងនិវត្តជននៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងបានរៀបចំរបាយការណ៍ចំណាយថវិកាកម្មវិធីប្រចាំខែមេសា ឆ្នាំ២០២២

- បង្កើន 3E's ដោយយកការសន្សំសំចៃ និងវិចារណកម្មថវិកាជាស្នូល

- បានរៀបចំលិខិតបទដ្ឋានគតិយុត្តផ្សេងៗចំនួន១៧ច្បាប់ និងធ្វើប័ណ្ណសម្គាល់ខ្លួនចំនួន១២ប័ណ្ណ

- បានរៀបចំពិធីបិទវគ្គបណ្តុះបណ្តាលស្តីពី កិច្ចការសភា

- បានសម្របសម្រួលជាមួយស្ថានទូតចិន ប្រចាំព្រះរាជាណាចក្រកម្ពុជា ត្រៀមរៀបចំកម្មវិធីប្រគល់ និងទទួលលើគម្រោងជួសជុល កែលម្អ នៅអគារក្រហមព្រឹទ្ធសភា

- បានជួសជុលកែលម្អអគារខុទ្ទកាល័យថ្នាក់ដឹកនាំ, ខុទ្ទកាល័យអគ្គលេខាធិការរងថ្មី និងជំនួយការ ព្រមទាំងបន្ទប់សម្រាប់អ្នកសារព័ត៌មាន និងជួសជុលជណ្តើរយន្ត

- បានរៀបចំទីកន្លែងធ្វើការ និងប្រព័ន្ធអគ្គិសនីជូនក្រុមសិក្សាស្រាវជ្រាវទូទៅ

- បានកែលម្អសួនច្បារ កាត់តម្រឹមស្មៅ មែកឈើ និងផ្កានានាចំនួន០៨ប្លង់

- បានចាត់ចែងកម្លាំង និងប្រើប្រាស់រថយន្តបោសសម្អាតតាមដងផ្លូវ ក្នុងបរិវេណព្រឹទ្ធសភា និងនៅជាប់របងខាងមុខព្រឹទ្ធសភា

- បានជួសជុល កែលម្អហេដ្ឋារចនាសម្ព័ន្ធ អគារ បណ្តាញទឹក, ការបិទថ្នាំនៅតាមជញ្ជាំងអគារសាលប្រជុំពេញអង្គ, ត្រួតពិនិត្យជណ្តើរយន្ត ត្រួតពិនិត្យសត្វកណ្តៀរ, ផ្លាស់ប្តូរគ្រឿងអគ្គិសនី គ្រឿងអេឡិចត្រូនិច គ្រឿងសង្ហារឹម, បិទលេខកូដសម្ភារសារពើភ័ណ្ឌ ព្រមទាំងបានប្រគល់សម្ភារៈការិយាល័យជូនអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន២៧៥គ្រឿង/លើក

- បានប្រចាំការត្រួតពិនិត្យម៉ាស៊ីនភ្លើងនៅតាមសាលប្រជុំ និងការប្រើប្រាស់ទឹក ភ្លើងក្រោយម៉ោងរដ្ឋបាល និងថ្ងៃឈប់សម្រាកចំនួន២៩លើក

- បានធ្វើរបាយការណ៍ស្តីពី លទ្ធផលការងាររបស់ព្រឹទ្ធសភាប្រចាំខែមេសា ឆ្នាំ២០២២ ទូលថ្វាយ**ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា

- បានធ្វើសម្រង់ស្ថិតិ បទបង្ហាញ របាយការណ៍ស្តីពី លទ្ធផលការងារព្រឹទ្ធសភា និងអគ្គ-លេខាធិការដ្ឋានព្រឹទ្ធសភាប្រចាំខែមេសា ឆ្នាំ២០២២ ព្រមទាំងបានផ្សព្វផ្សាយទៅតាមអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងក្រសួង ស្ថាប័ននានា។

**៤.២-ការងារសេវាច្បាប់៖**

- បានទទួលសេចក្តីព្រាងច្បាប់ចំនួន០២ច្បាប់ ពីរាជរដ្ឋាភិបាល និងរដ្ឋសភា

- បានទទួលព្រះរាជក្រម ព្រះរាជក្រឹត្យ អនុក្រឹត្យ សារាចរណែនាំ ប្រកាស សេចក្តីសម្រេច សេចក្តីជូនដំណឹង របាយការណ៍ និងលិខិតផ្សេងៗចំនួន៥០៨ច្បាប់

- បានធ្វើកំណត់បង្ហាញរបាយការណ៍សវនកម្មចំនួន០៦ច្បាប់

- បន្តចងក្រងបញ្ជីអត្ថបទច្បាប់ ដែលព្រឹទ្ធសភាបានពិនិត្យ និងឱ្យយោបល់តាមឆ្នាំ និងនីតិកាលនីមួយៗ

- បានធ្វើបច្ចុប្បន្នភាពប្រតិទិនសម័យប្រជុំព្រឹទ្ធសភា នីតិកាលទី៤ (ឆ្នាំ២០២២-២០២៤)។

៤.៣-ការងារស្រាវជ្រាវ៖

- បានសិក្សាស្រាវជ្រាវ និងធ្វើសំយោគឯកសារព័ត៌មានជាតិ និងអន្តរជាតិ តាមវិស័យចំនួន ៤៤អត្ថបទ

- បានតាមដានការកាត់បន្ថយចំណាយរបស់រាជរដ្ឋាភិបាល និងសិក្សាស្រាវជ្រាវ ចងក្រងការអនុវត្តការធ្វើកំណែទម្រង់គោលនយោបាយចំណូល-ចំណាយ ក្នុងអំឡុងពេលនៃការរាតត្បាតជាសកលនៃជំងឺកូវីដ-១៩

- បានផលិតព័ត៌មានច្បាប់ជាតិ និងអន្តរជាតិចំនួន៤៨អត្ថបទ

- បានផលិតព្រឹត្តិបត្រព័ត៌មានថវិកា និងសេដ្ឋកិច្ចប្រចាំខែមេសា ឆ្នាំ២០២២ ចំនួន០៤ច្បាប់។

៤.៤-ការងារព័ត៌មាន និងទំនាក់ទំនងសាធារណៈ៖

- បានរៀបចំទិន្នន័យច្បាប់ (Legal Database) របស់ព្រឹទ្ធសភា

- បានធ្វើបច្ចុប្បន្នភាពគេហទំព័រ (Laws.gov.kh) ប្រមូលព័ត៌មានទាក់ទងនឹងច្បាប់ អនុក្រឹត្យ ព្រះរាជក្រឹត្យ និងច្បាប់ដែលបានធ្វើវិសោធនកម្ម និងអនុម័តរួចចំនួន០២លើក

- បានចុះត្រួតពិនិត្យ តាមដានប្រព័ន្ធ Network Internet Wi-Fi និងដាក់កម្មវិធីកម្ចាត់មេរោគ Update Files Antivirus ព្រមទាំងបានដោះស្រាយបញ្ហាផ្សេងៗដែលពាក់ព័ន្ធនឹងជំនាញបច្ចេក-វិទ្យាព័ត៌មានចំនួន៨៨គ្រឿង។ បានបញ្ចូលព័ត៌មានស្តីពី សកម្មភាពរបស់ថ្នាក់ដឹកនាំ សមាជិកព្រឹទ្ធសភា និងថ្នាក់ដឹកនាំនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាលើគេហទំព័រព្រឹទ្ធសភាចំនួន ១២៦ប្រធានបទ

- បានបន្តបំពាក់ឧបករណ៍អេឡិចត្រូនិចមានដូចជា កុំព្យូទ័រយួរដៃ កុំព្យូទ័រលើតុ និងIpad ជូនសមាជិកព្រឹទ្ធសភា និងអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន៥៨គ្រឿង

- បានទទួលសៀវភៅច្បាប់ ឯកសារ និងសៀវភៅជំនាញផ្សេងៗចំនួន២៧ក្បាល ព្រមទាំងបានបោះត្រា ចុះបញ្ជីសៀវភៅ បិទប័ណ្ណខ្ចី និងសងសៀវភៅចំនួន២៥ក្បាល

- បានប្រមូល ដកស្រង់ ចងក្រង និងផ្សព្វផ្សាយព័ត៌មានសង្ខេបប្រចាំថ្ងៃចំនួន៤៩លើក និងទស្សនព័ត៌មានប្រចាំថ្ងៃចំនួន២២លើក

- បានប្រមូល និងផ្សព្វផ្សាយព័ត៌មានក្នុង Chanel Telegram ព័ត៌មានប្រចាំថ្ងៃចំនួន ១,៤៧៤ប្រធានបទ

- បានប្រើប្រាស់ E-Mail ជាមធ្យោបាយសម្រាប់ដំណើរការចរន្តឯកសារផ្ទៃក្នុងនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

- បន្តអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មាន រដ្ឋបាលអេឡិចត្រូនិច ការប្រើប្រាស់Zoom ប្រព័ន្ធសំឡេង

ការផ្សព្វផ្សាយតាមបណ្តាញសង្គម បណ្ណាល័យ បណ្ណសារដ្ឋានអេឡិចត្រូនិច ការងារព័ត៌មាន ការផលិតខ្សែវីដេអូ ការបោះពុម្ព និងការថតផ្សព្វផ្សាយអំពីសម័យប្រជុំព្រឹទ្ធសភាឱ្យបានលឿន ល្អ និងរលូន។

**៤.៥-ការងារពិធីការ៖**

- បានរៀបចំចាត់ចែង និងសម្របសម្រួលជូនថ្នាក់ដឹកនាំ សមាជិកព្រឹទ្ធសភា និងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ជួបពិភាក្សាការងារ ចូលរួមកិច្ចប្រជុំ និងពិធីផ្សេងៗចំនួន២១លើក
- បានផលិត និងផ្សព្វផ្សាយព្រឹត្តិបត្រព័ត៌មានកិច្ចការអន្តរជាតិ ប្រចាំខែមេសា ឆ្នាំ២០២២ ចំនួន០១ច្បាប់
- បានកសាងជំនួយស្មារតី ធ្វើលិខិតអបអរសាទរ និងលិខិតថ្លែងអំណរគុណ ជូនថ្នាក់ដឹកនាំព្រឹទ្ធសភាចំនួន០៨លើក។

**II-លទ្ធផលការងារគាំទ្រលើមុខងារឆាំង៥៖**

- បានពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន១៨១ច្បាប់
- បានតុបតែងលម្អ តាំងពិព័រណ៍រូបភាពចំនួន១៦លើក
- បានធ្វើលិខិតបេសកកម្មជូនសមាជិកព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន៧០ច្បាប់ ស្មើនឹង២៧៩នាក់ និងលិខិតអនុញ្ញាតច្បាប់ជូនសមាជិកព្រឹទ្ធសភាចំនួន០១ច្បាប់ ស្មើនឹង០១នាក់
- បានផ្តល់សេវាថវិកាជូនថ្នាក់ដឹកនាំ សមាជិកព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខា-ធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងបានទូទាត់ការចំណាយផ្សេងៗចំនួន៥២៧លើក
- បានផ្គត់ផ្គង់វត្ថុអនុស្សាវរីយ៍ គ្រឿងបរិក្ខារ ប្រេងឥន្ធនៈ សម្ភារអនាម័យ សម្ភារការិយាល័យ ភេសជ្ជៈ និងអាហារសម្រន់សម្រាប់បម្រើដល់កិច្ចប្រជុំ និងជូនគ្រប់អង្គភាពចំណុះអគ្គលេខា-ធិការដ្ឋានព្រឹទ្ធសភាចំនួន៦៦សំណើ
- បានរៀបចំសម្អាត តុបតែងលម្អសាលប្រជុំ បម្រើសេវាភេសជ្ជៈ អាហារសម្រន់ក្នុងកិច្ចប្រជុំ និងពិធីផ្សេងៗចំនួន៣៣លើក មានអ្នកចូលរួមចំនួន៤៤២នាក់
- បានសួរសុខទុក្ខនិវត្តជននៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន០៥នាក់
- បានឧបត្ថម្ភថវិកាជូនក្រុមគ្រូពេទ្យមកប្រចាំការក្នុងម៉ោងរដ្ឋបាល ក្នុងឱកាសបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរចំនួន៤,០០០,០០០រៀល
- បានចែកទឹកអាល់កុលលាងដៃសម្លាប់មេរោគចំនួន៣៣០លីត្រ តាមការស្នើសុំរបស់អង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

- បានថតចម្លងឯកសារចំនួន៣,២៥៩ច្បាប់ និងចងក្រងធ្វើជាសៀវភៅចំនួន១៩៩ក្បាល អស់ក្រដាសចំនួន២០,៧៦០សន្លឹក

- បានផ្តល់សេវាដឹកជញ្ជូនសម្រាប់ថ្នាក់ដឹកនាំ សមាជិកព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចុះបំពេញបេសកកម្មនៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្ត ក្រុង ចំនួន១៧២លើក ស្មើនឹង៤៨៤នាក់

- បានផលិត និងផ្សព្វផ្សាយខ្សែវីដេអូព័ត៌មានព្រឹទ្ធសភាចំនួន២៦លើក

- បានថត និងផ្សព្វផ្សាយព័ត៌មានស្តីពី សកម្មភាពការងាររបស់ថ្នាក់ដឹកនាំ សមាជិកព្រឹទ្ធសភា និងថ្នាក់ដឹកនាំនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា តាមប្រព័ន្ធTwitter, Youtube និងFacebook ចំនួន៣៣៧លើក

- បានការពារសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់ក្នុងកិច្ចប្រជុំ និងពិធីផ្សេងៗដោយប្រើប្រាស់កម្លាំងសន្តិសុខផ្ទៃក្នុងចំនួន១១លើក។

## III-**ទិសដៅការងារខែឧសភា ឆ្នាំ២០២២**

***-បន្តអនុវត្តវិធានការរបស់ក្រសួងសុខាភិបាល "៣ការពារ ៣កុំ" ពាក់ម៉ាស់ ធ្វើតេស្តពេលចាំបាច់ និងវិធានការចាំបាច់ផ្សេងៗទៀត (ដាក់ឱ្យនៅដាច់ដោយឡែក រឹតត្បិតឡីស័ក) ប្រឆាំងនឹងជំងឺកូវីដ-១៩ និងបន្តយកចិត្តទុកដាក់ធ្វើការងារមនុស្សធម៌ក្នុង និងក្រៅស្ថាប័នឱ្យបានទាន់ពេលវេលា៖***

+យកចិត្តទុកដាក់តាមដានសុខភាពរបស់សមាជិកព្រឹទ្ធសភា

+យកចិត្តទុកដាក់តាមដានសុខភាព លក្ខខណ្ឌការងារ និងជីវភាពទូទៅក្នុងក្របខណ្ឌស្ថាប័នទាំងមូល

+ត្រៀមបត់បែនដើម្បីប្រឈមនឹងការគំរាមកំហែងថ្មីៗ កូវីដ-១៩ ជំងឺរាតត្បាតថ្មី គ្រោះធម្មជាតិ ការប្រែប្រួលអាកាសធាតុ ផលវិបាកសេដ្ឋកិច្ច សង្គម វប្បធម៌ បរិស្ថាន សភាពការណ៍តំបន់ និងពិភពលោក ដូចជាអំពើភេរវកម្ម អំពើឧក្រិដ្ឋកម្ម ការវាយប្រហារ និងជំរិតខាងបច្ចេកវិទ្យាព័ត៌មាន

+បន្តយកចិត្តទុកដាក់បរិស្ថាន អនាម័យ សួនច្បារ សំរាម ហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត បច្ចេកទេស បច្ចេកវិទ្យា អគារការិយាល័យ សុវត្ថិភាព សន្តិសុខ សណ្តាប់ធ្នាប់ និងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ

+សមត្ថភាពប្រើប្រាស់ និងថែទាំបច្ចេកទេស គ្រប់គ្រងការប្រើប្រាស់កម្លាំង និងបច្ចេក-វិទ្យាព័ត៌មានឱ្យបានសមស្របតាមការប្រែប្រួល និងតម្រូវការថ្មី ដោយធានាបានសន្តិសុខ សុវត្ថិភាព វឌ្ឍនភាព និងនិរន្តរភាព

***-បន្តប្រក្រតីភាព និងនិរន្តរភាពការងាររបស់ស្ថាប័នលើគ្រប់វិស័យ និងមុខងារទាំង៥ ក្នុងលក្ខណៈបត់បែន ទន់ភ្លន់ក្នុងសភាពការណ៍ចល័ត ដើម្បីធានាបរិមាណ និងគុណភាពការងារ***

+ជានានិរន្តរភាព ប្រក្រតីភាព ប្រសិទ្ធភាព សុវត្ថិភាពនៃការដឹកនាំ និងគ្រប់គ្រងប្រព័ន្ធការងាររដ្ឋបាល ហិរញ្ញវត្ថុ បច្ចេកទេស ព័ត៌មាន សន្តិសុខ បច្ចេកវិទ្យា នីតិវិធី ពិធីការ ការស្រាវជ្រាវ ទំនាក់ទំនងក្នុង-ក្រៅស្ថាប័ន និងក្នុង-ក្រៅប្រទេស ព្រមទាំងជំនួយកិច្ចសហប្រតិបត្តិការនានា

- ដំណើរឆ្ពោះទៅកាន់មូលដ្ឋានរបស់សមាជិកព្រឹទ្ធសភា ក្នុងរយៈពេលវិស្សមកាល ចាប់ពីខែឧសភា ដល់ខែសីហា ឆ្នាំ២០២២

- បង្កើនគុណភាព និងប្រសិទ្ធភាពផ្តល់សេវាជូនសមាជិកព្រឹទ្ធសភា ឱ្យបានល្អប្រសើរ និងគ្រប់ជ្រុងជ្រោយក្នុងដំណើរចុះទៅមូលដ្ឋាន និងជួបសវនាការជាមួយក្រសួង ស្ថាប័ននានា

- ត្រៀមសហការធ្វើរបាយការណ៍ចន្លោះសម័យប្រជុំលើកទី៨ និងលើកទី៩ ឱ្យបានទាន់ពេលវេលា និងល្អប្រសើរ។

## ១- មុខងារនីតិកម្ម

- ត្រៀមរៀបចំប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ប្រជុំពេញអង្គ និងប្រជុំព្រឹទ្ធសភាជាវិសាមញ្ញ នីតិកាលទី៤ មានរបៀបវារៈដូចខាងក្រោម៖

១-ការបោះឆ្នោតជ្រើសរើសសមាជិកឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមចំនួន០១រូប ជំនួសសមាជិកដែលទទួលមរណភាព

២-សេចក្តីព្រាងច្បាប់ស្តីពី វិសោធនកម្មមាត្រា១៤០ នៃច្បាប់ស្តីពី ការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

៣-សេចក្តីព្រាងច្បាប់ស្តីពី សុវត្ថិភាពម្ហូបអាហារ។

## ២- មុខងារតាមដានការអនុវត្តច្បាប់ និងគោលនយោបាយនានា

- ត្រៀមសហការ និងសម្របសម្រួលការងារជូនថ្នាក់ដឹកនាំ និងសមាជិកព្រឹទ្ធសភាជួបសវនាការ ពិភាក្សាការងារជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធនានា និងការចុះបេសកកម្ម នៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្ត ក្រុងនានា។

## ៣- មុខងារតំណាង

-ត្រៀមរៀបចំជូនថ្នាក់ដឹកនាំ និងសមាជិកព្រឹទ្ធសភា អញ្ជើញចុះទៅប្រាស្រ័យទាក់ទងជាមួយប្រជាពលរដ្ឋ អាជ្ញាធរដែនដី នៅមូលដ្ឋាន ព្រមទាំងចូលរួមក្នុងពិធីសាសនា និងផ្លូវការផ្សេងៗនៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្ត ក្រុងនានា។

## ៤- មុខងារសហប្រតិបត្តិការអន្តរជាតិ

-ត្រៀមរៀបចំជូនគណៈប្រតិភូជាន់ខ្ពស់ព្រឹទ្ធសភា អញ្ជើញបំពេញទស្សនកិច្ចជាផ្លូវការនៅសាធារណរដ្ឋសង្គមនិយមវៀតណាម និងសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ

-ត្រៀមរៀបចំមហាសន្និបាតអាយប៉ាលើកទី៤៣ ដែលកម្ពុជាធ្វើជាម្ចាស់ផ្ទះ

-ផ្តល់សេវាចាំបាច់បម្រើការងារសហប្រតិបត្តិការតំបន់ និងអន្តរជាតិ ការចូលរួមមហាសន្និបាត សិក្ខាសាលា វេទិកានានា កម្មវិធីជំនួប កម្មវិធីផ្លូវការ ការស្វែងរកជំនួយ និងកិច្ចសហប្រតិបត្តិការជាមួយដៃគូសំខាន់ៗ អភិវឌ្ឍស្ថាប័ន ការបណ្តុះបណ្តាលធនធានមនុស្សតាមការកំណត់ និងក្នុងលក្ខណៈបត់បែនជាការតម្រូវនៃបរិបទកូវីដ-១៩

-តាមដានបញ្ហាចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នា(MOU) ជាមួយឥណ្ឌា និងប៉ាគីស្ថាន ការអនុវត្តកម្មវិធីវិទ្យាស្ថានក្រសួងការបរទេស មជ្ឈមណ្ឌលសភាអាស៊ី(PCA) និងវិទ្យាស្ថានចក្ខុវិស័យអាស៊ី។ ការចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នា(MOU) ឡើងវិញជាមួយដៃគូសំខាន់ៗរបស់មជ្ឈមណ្ឌលសភាអាស៊ី(PCA) លេខាធិការដ្ឋាន(APF) លេខា-ធិការដ្ឋាន(AIPA) និង(KPI) ព្រមទាំងដៃគូថ្មីមួយចំនួនទៀត (វិទ្យាស្ថានសភាឡាវ)

-ត្រៀមសហប្រតិបត្តិការជាមួយមជ្ឈមណ្ឌលសភាអាស៊ី(PCA) តាមការអនុវត្តកម្មវិធីបណ្តុះបណ្តាលជាបន្តបន្ទាប់

-ត្រៀមរៀបចំការប្រជុំជូនក្រុមយន្តការនានារបស់ព្រឹទ្ធសភាតាមប្រព័ន្ធវីដេអូ និងដោយផ្ទាល់

-ត្រៀមចុះអនុស្សរណៈជាថ្មីជាមួយរដ្ឋសភាបារាំង

-ត្រៀមទទួលគណៈប្រតិភូដឹកនាំដោយឯកឧត្តម **VINCENT EBLE** ប្រធានក្រុមមិត្តភាពសមាជិកព្រឹទ្ធសភាបារាំង-កម្ពុជា និងជាអនុប្រធានគណៈកម្មការហិរញ្ញវត្ថុនៃព្រឹទ្ធសភាបារាំង មកបំពេញបេសកកម្មនៅព្រះរាជាណាចក្រកម្ពុជា នាខែឧសភា

-បន្តសកម្មភាពសហប្រតិបត្តិការជាមួយដៃគូនានា ដើម្បីអនុវត្តយុទ្ធសាស្ត្រថវិកាតិច សកម្មភាពច្រើន

-សហការជាមួយដៃគូសំខាន់ៗ អនុវត្តកម្មវិធីសហប្រតិបត្តិការ (PCA, ITECH, MFE, APF) និងបន្តស្វែងរកជំនួយសម្រាប់អភិវឌ្ឍស្ថាប័ន ធនធានមនុស្ស និងបច្ចេកវិទ្យាព័ត៌មាន ព្រមទាំងការចូលរួមមហាសន្និបាត និងវេទិកានានាក្នុងក្របខណ្ឌ (IPU, APF, AIPA...)។

**៥- មុខងារអភិវឌ្ឍន៍ស្ថាប័ន**

-បន្តរៀបចំយុទ្ធសាស្ត្រថវិកា៣ឆ្នាំរំកិល និងគម្រោងថវិកាឆ្នាំ២០២៣

-តាមដាន និងសម្របសម្រួលជាមុនជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អំពីគម្រោងស្នើកសាងអគារថ្មី២ខ្នង គម្រោងស្នើសុំជំនួយពីរាជរដ្ឋាភិបាលនៃប្រទេសជាមិត្តសម្រាប់នីតិកាលថ្មី

ខាងមុខ និងការស្នើសុំឥណទានបន្ថែមពីរាជរដ្ឋាភិបាល

-ការបើកប្រាក់បៀវត្ស ប្រាក់ឧបត្ថម្ភ និងផលប្រយោជន៍ផ្សេងៗរបស់សមាជិកព្រឹទ្ធសភា និងមន្ត្រីរាជការសម្រាប់ខែឧសភា ឆ្នាំ២០២២ ឱ្យបានទាន់ពេលវេលា

-យកចិត្តទុកដាក់អនុវត្តគោលការណ៍ 3E's ដោយផ្តោតលើការងារជាអាទិភាព សំខាន់ ចាំបាច់ និងបន្ទាន់បំផុត៖

+ការវិនិយោគលើវិស័យបច្ចេកវិទ្យាព័ត៌មាន និងវិស័យបច្ចេកទេស គឺជាស្នូលសំខាន់នៃការអភិវឌ្ឍស្ថាប័ន និងការលើកកម្ពស់សមត្ថភាពលើគ្រប់វិស័យ ព្រមទាំងជំនាញរបស់មន្ត្រីបុគ្គលិក

+ធ្វៀតបញ្ចូលការប្រើប្រាស់គ្រឿងយន្តអគ្គិសនី និងពង្រីកការបំភ្លឺដោយថាមពលព្រះអាទិត្យ ដើម្បីថែរក្សាធម្មជាតិបៃតង កាត់បន្ថយចំណាយ និងការប្រើកម្លាំងមនុស្ស ហើយចាប់ផ្តើមអនុលោមតាមបរិបទបរិស្ថានទំនើប ដែលប្រឆាំងការប្រែប្រួលអាកាសធាតុ (ការគ្រប់គ្រងសំរាម និងផ្លាស្ទិក)

-បញ្ចប់ការរៀបចំជួសជុលកែលម្អបន្ទប់សម្រាប់អ្នកសារព័ត៌មាន នៅក្រោមអគារក្រហម

-ត្រៀមធ្វើជំរឿនសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ តម្រូវការ និងការប្រឈម

-បន្តកសាង និងធ្វើបច្ចុប្បន្នភាព គោលការណ៍ គោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត បម្រើឱ្យការគ្រប់គ្រងក្នុងបរិបទកែទម្រង់រដ្ឋបាលសាធារណៈ និងហិរញ្ញវត្ថុសាធារណៈ

-ការអនុវត្តផែនការបណ្តុះបណ្តាលធនធានមនុស្សតាមកិច្ចសហប្រតិបត្តិការជាមួយដៃគូនានា

-បង្កើនការគ្រប់គ្រងអគារ និងសារពើភ័ណ្ឌ ការគ្រប់គ្រងសន្តិសុខ សណ្តាប់ធ្នាប់ អនាម័យ និងការគ្រប់គ្រងការប្រើប្រាស់ Internet

-ទំនាក់ទំនង និងជំរុញសុំការគាំទ្រពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្ថានទូតចិន គម្រោងជំនួយក្នុងការសាងសង់អគារសាលប្រជុំពេញអង្គថ្មី និងបំពាក់សម្ភារមជ្ឈមណ្ឌលប្រព័ន្ធព័ត៌មានវិទ្យា(ICT)

-បង្កើនគុណភាពនៃការថត និងផ្សព្វផ្សាយអំពីសម័យប្រជុំពេញអង្គព្រឹទ្ធសភា

-បន្តកសាងប្រព័ន្ធគ្រប់គ្រងទិន្នន័យ គ្រប់គ្រងព័ត៌មាន គ្រប់គ្រងរដ្ឋបាល កម្មវិធីបណ្ណសារអេឡិចត្រូនិច និងបណ្ណាល័យអេឡិចត្រូនិច ត្រូវបន្តសហការយ៉ាងសកម្មជាមួយភាគីចិន

-ត្រៀមបញ្ជូនមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន០១រូប ចូលរួមវគ្គបណ្តុះបណ្តាលកិច្ចការសភា នៅសាលារដ្ឋបាលជាតិបារាំង។

IV-**សេចក្តីសន្និដ្ឋាន**

ក្នុងខែមេសានេះ ថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ក៏ដូចប្រជាជនកម្ពុជាទូទាំងប្រទេស បានចូលរួមពិធីបុណ្យចូលឆ្នាំថ្មី ប្រពៃណីជាតិខ្មែរ យ៉ាងសប្បាយរីករាយបន្ទាប់ពីអាក់ខានរយៈពេល២ឆ្នាំកន្លងមក។ ទន្ទឹមនឹងនេះ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភានៅតែបន្តការងារជាអាទិភាពលើមុខងារស្នូលទាំង៣របស់ខ្លួន ដោយបានរៀបចំ និងចាត់ចែងការប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ចំនួន០២លើក និងប្រជុំពេញអង្គព្រឹទ្ធសភា នីតិកាលទី៤បានដោយរលូន។ ជាពិសេសក្នុងបរិបទនៃដំណើរឆ្ពោះទៅកាន់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ ក្នុងរយៈពេលវិស្សមកាល៣ខែ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បន្តផ្តោតការយកចិត្តទុកដាក់ខ្ពស់ជាអាទិភាពលើមុខងារតាមដានការអនុវត្តច្បាប់ និងមុខងារតំណាង ដោយបានផ្តល់សេវាជូនគណៈកម្មការជំនាញទាំង១០ ចុះបំពេញបេសកកម្ម ជួបសវនាការការងារជាមួយក្រសួង និងស្ថាប័ននានា ព្រមទាំងអមដំណើរសមាជិកព្រឹទ្ធសភា ចុះជួបសំណេះសំណាល សាកសួរសុខទុក្ខប្រជាពលរដ្ឋ ក្រុមប្រឹក្សាឃុំ-សង្កាត់ និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ ដើម្បីឈ្វេងយល់អំពីការអភិវឌ្ឍមូលដ្ឋាន ដោះស្រាយទុក្ខលំបាករបស់ប្រជាពលរដ្ឋ និងបញ្ហាប្រឈមនានា ផ្សព្វផ្សាយវិធានការរបស់ក្រសួងសុខាភិបាល ជាពិសេសអប់រំប្រជាពលរដ្ឋឱ្យរៀនរស់ជាមួយជំងឺកូវីដ-១៩ នៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្ត ក្រុងនានា។ ចំពោះមុខងារកិច្ចសហប្រតិបត្តិការអន្តរជាតិ បានរៀបចំ និងចាត់ចែងបានយ៉ាងល្អប្រសើរជូនថ្នាក់ដឹកនាំ និងសមាជិកព្រឹទ្ធសភា ជួបពិភាក្សាការងារជាមួយគណៈប្រតិភូអន្តរជាតិ ជាពិសេសដំណើរទស្សនកិច្ចជាផ្លូវការនៅសាធារណរដ្ឋកូរ៉េ ទទួលបានលទ្ធផលល្អ និងជាកាលានុវត្តភាពថ្មីមួយបន្ថែមទៀត ក្នុងការបង្កើនកម្រិតកិច្ចសហប្រតិបត្តិការទ្វេភាគីកម្ពុជា-កូរ៉េ ឱ្យកាន់តែល្អប្រសើរជាលំដាប់។

មន្ត្រីរាជការទាំងអស់ ត្រូវបន្តយកចិត្តទុកដាក់ចូលរួមប្រយុទ្ធប្រឆាំងនឹងការរីករាលដាលនៃជំងឺកូវីដ-១៩នេះ ដោយបន្តអនុវត្តឱ្យបានខ្ជាប់ខ្ជួនតាមវិធាន និងការណែនាំរបស់ក្រសួងសុខាភិបាល ឱ្យបានម៉ត់ចត់ និងល្អប្រសើរ។

ថ្ងៃពុធ ៤កើត ខែពិសាខ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០២២

**អគ្គលេខាធិការ**

**អ៊ុំ សារឹទ្ធ**